# សលាកប័ត្រព័ត៌មាន៖ សហគមន៍នេសាទ និងគម្រោងអភិវឌ្ឍន៍នៅតំបន់ឆ្នេរនៃប្រទេសកម្ពុជា

**ទិដ្ឋភាពរួម៖** គម្រោងអភិវឌ្ឍន៍នៅតែបន្តគំរាមកំហែងដល់អត្ថិភាពនៃសហគមន៍នេសាទ ("សហគមន៍នេសាទ") នៅតំបន់ឆ្នេរ ដោយសារដីដែលពួកគេពឹងអាស្រ័យសម្រាប់ចិញ្ចឹមជីវិត កំពុងរងការរំលោភបំពានយក និងបំផ្លិចបំផ្លាញ។ សលាកប័ត្រព័ត៌មាននេះត្រូវបានចងក្រងឡើង ដើម្បីបំពេញបន្ថែមទៅលើសលាកប័ត្រព័ត៌មានមុនចំនួនពីរដែលចេញផ្សាយដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាក្នុងឆ្នាំ២០២១ និង២០២២ និងបូកសរុបលទ្ធផលនៃការស្រាវជ្រាវទៅលើគម្រោងអភិវឌ្ឍន៍ចំនួនពីរ កំពុងគំរាមកំហែងសហគមន៍នេសាទនៅតំបន់ឆ្នេរនៃខេត្តកំពត និងខេត្តកែប៖ ទីមួយ គឺពាក់ព័ន្ធនឹងក្រុមហ៊ុន អុមនី កំពត ខូ អិលធីឌី ("ក្រុមហ៊ុនអុមនី") និងមួយទៀតពាក់ព័ន្ធនឹងក្រុមហ៊ុន ជីងគ័រ អាហារ៍ណា នីហារ៍ណា ខូអិលធីឌី ("ក្រុមហ៊ុនជីងគ័រ")។ មានគម្រោងអភិវឌ្ឍន៍មួយចំនួនទៀតដែលគំរាមកំហែងសហគមន៍នេសាទ ក៏ត្រូវបានលើកយកមកបង្ហាញនៅក្នុងសលាកប័ត្រព័ត៌មាននេះផងដែរ។ បើគម្រោងទាំងនេះនៅតែបន្ត នឹងបង្កឱ្យមានផលប៉ះពាល់ទៅដល់សហគមន៍នេសាទនៅក្នុងខេត្តទាំងពីរ។ សលាកប័ត្រព័ត៌មាននេះ បញ្ចប់ដោយបង្ហាញនូវអនុសាសន៍ជាក់លាក់មួយចំនួនទៅដល់រាជរដ្ឋាភិបាលកម្ពុជា ("រាជរដ្ឋាភិបាល") និងធុរកិច្ច ដើម្បីលើកកម្ពស់ការគោរពសិទ្ធិនេសាទ សិទ្ធិដីធ្លី និងសេរីភាពមូលដ្ឋានសម្រាប់សហគមន៍នេសាទនៅតំបន់ឆ្នេរនិងនៅទូទាំងប្រទេស។

## ១. សេចក្តីផ្តើម

សហគមន៍នេសាទត្រូវបានបង្កើតឡើងជាផ្លូវការដោយព្រះរាជក្រឹត្យឆ្នាំ២០០៥ ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋខ្មែររួមគ្នាបង្កើតសហគមន៍នេសាទនៅក្នុងតំបន់របស់ខ្លួន[1] ក្នុងគោលបំណងបង្កើនឱ្យមានការគ្រប់គ្រងជលផលថ្នាក់មូលដ្ឋានកាន់តែប្រសើរឡើង។ សហគមន៍នេសាទគឺជាម៉ាស៊ីនសេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលរៀបចំរចនាសម្ព័ន្ធជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋរាប់ពាន់នាក់ និងបានផ្តល់ជាស្បៀងអាហារផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេសកម្ពុជា។ សហគមន៍នេសាទបានផ្តល់ការងារដល់ប្រជាពលរដ្ឋខ្មែរជាច្រើនលាននាក់ និងរួមវិភាគទានយ៉ាងសំខាន់ទៅដល់សុវត្ថិភាពស្បៀងក្នុងស្រុក។ ប្រពលរដ្ឋខ្មែរ គឺជាអ្នកបរិភោគត្រីក្នុងចំណោមប្រជាពលរដ្ឋនៃប្រទេសដ៏ទៃទៀតដែលបរិភោគត្រីច្រើនជាងគេបំផុតនៅក្នុងពិភពលោក ក្នុងអត្រាជា

[1] មាត្រា១នៃព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ (ការបកប្រែក្រៅផ្លូវការ, ឆ្នាំ ២០០៥)។

អ្នកបរិភោគសាច់ត្រីត្រូវបានប៉ាន់ប្រមាណចន្លោះពី ៣៧,៥ ទៅ ៦៧ គីឡូក្រាម សម្រាប់ប្រជាពលរដ្ឋម្នាក់ជារៀងរាល់ឆ្នាំ ហើយ៧៥ភាគរយនៃប្រជាពលរដ្ឋខ្មែរទទួលទានប្រូតេអ៊ីនដែលទទួលបានពីសាច់ត្រី[2] ។ ព្រោះហេតុនេះហើយ សហគមន៍នេសាទគឺជាតួអង្គដ៏សំខាន់ក្នុងការគាំទ្រជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងសង្គមខ្មែរ។

ការចិញ្ចឹមជីវិតដែលបានមកពីរបរនេសាទ ធ្វើឱ្យសមាជិកសហគមន៍នេសាទទទួលបាននូវសិទ្ធិមនុស្សសំខាន់ៗមានដូចជា សិទ្ធិមានលំនៅឋាន ដែលជាសិទ្ធិចាំបាច់បន្ទាន់មួយដើម្បីការពារពួកគេនៅក្នុងបរិបទនៃជំងឺកូវីដ១៩ សិទ្ធិមានចំណីអាហារ សិទ្ធិមានសុខភាព និងសិទ្ធិទទួលបានការអប់រំសម្រាប់កុមារ។ ទោះយ៉ាងណាជីវភាពរស់នៅរបស់ហគមន៍នេសាទ បានរងការគំរាមកំហែងដោយការកើនឡើងនៃគម្រោងអភិវឌ្ឍន៍ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះជាពិសេសគឺនៅតំបន់សមុទ្រ និងតំបន់ឆ្នេរសមុទ្រ រួមទាំងគោលដៅទេសចរណ៍ផងដែរដែលទាក់ទាញយ៉ាងខ្លាំងដល់អ្នកវិនិយោគ។ តាមរយៈការទន្ទ្រានយកដែននេសាទ ដែលសហគមន៍អាស្រ័យផលដើម្បីទ្រទ្រង់ជីវភាពនោះ គម្រោងអភិវឌ្ឍន៍ជាច្រើនរារាំងសហគមន៍ពីការនេសាទ និងបានបំផ្លាញបរិស្ថាន ដែលជាការគំរាមកំហែងធ្ងន់ធ្ងរចំពោះការរស់រានមានជីវិត និងរបៀបផែនរស់នៅរបស់សហគមន៍នេសាទ និងធ្វើឱ្យប៉ះពាល់ដល់សន្តិសុខស្បៀងនៅក្នុងប្រទេសកម្ពុជា។

## ២. បញ្ហាសំខាន់ៈ ការបន្តគំរាមកំហែងនៃការអភិវឌ្ឍចំពោះសហគមន៍នេសាទតំបន់ឆ្នេរក្នុងខេត្តកំពត និងកែប

នៅពីខែឧសភា ឆ្នាំ២០២២ នៅក្នុងពិធីបើកការដ្ឋានសាងសង់កំពង់ផែពហុបំណង និងភ័ស្តុភារដ៏ធំមួយដោយក្រុមហ៊ុនកំពង់ផែកំពតឡូជីសស្ទីក ខូអិលធីឌី លើផ្ទៃដីដែលបានធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋជាង៦០០ហិកតា[3] នៅក្នុងសង្កាត់ព្រែកត្នោត ខេត្តកំពត រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ("ដ.ន.ស") និងក្រសួងសាធារណការ និងដឹកជញ្ជូន បាននិយាយថាកំពង់ផែនេះគឺជាកាតាលីករសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងជួយឱ្យកម្ពុជាកាន់តែរុងរឿង ជាប្រទេសដែលមានចំណូលខ្ពស់នៅត្រឹមឆ្នាំ២០៥០។[4] រាជរដ្ឋាភិបាលកម្ពុជាមានបំណងបង្កើនវិស័យទេសចរណ៍ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចដែលឈានទៅដល់ការអនុញ្ញាតឱ្យដំណើរការនូវគម្រោងអភិវឌ្ឍន៍មួយចំនួននៅក្នុងខេត្តកំពត និងកែប នាពេលថ្មីៗនេះបន្ថែមលើគម្រោងកំពង់ផែពហុបំណង មានដូចជាក្រុមហ៊ុន ហ្វ្រេន រីវើរ៉ា ម៉ារីណា[5] កំពង់ផែទេសចរណ៍អន្តរជាតិកំពត[6] ការ

[2] សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីជលផល, (គេហទំព័រ, ចូលទៅអានថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២)។
[3] ម៉ិច ដារ៉ា "ដីសមុទ្រទំហំ ៦០០ហិកតាត្រូវបានប្រគល់ឱ្យក្រុមហ៊ុនឯកជនអភិវឌ្ឍគម្រោងកំពង់ផែកំពត" (វីអូឌី ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២).
[4] សុខ សិទ្ធិកា "កំពង់ផែកំពតតម្លៃ ១.៥ កោដិដុល្លារចាប់ផ្តើមសាងសង់" (ខ្មែរថាមស៍ ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២); អ៊ីវ៉ាន់ ហ្វ្រេឌ្រីច កាណូ "កំពង់ផែអន្តរជាតិកំពតថ្មីគ្រោងចំណាយថវិកា ១.៥ កោដិដុល្លារ" (ខ្មែរថាមស៍ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២); ព័ត៌មានអ៊ីអេស៊ី "កំពង់ផែពហុបំណងនៅកំពតនឹងផ្តល់ការងារប្រមាណ១០០០០កន្លែងដល់ប្រជាពលរដ្ឋ" (ព័ត៌មានអ៊ីអេស៊ី ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២)។
[5] គី កុសល "រមណីយដ្ឋានកំពតថ្មីតម្លៃ២៣កោដិដុល្លារ" (ខ្មែរថាមស៍ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧); "ផាឡាសៈ ការយល់ព្រមលើគម្រោងអភិវឌ្ឍន៍តម្លៃ ២៣.២ កោដិដុល្លារនៅប្រទេសកម្ពុជា" ( ប៊ីលដឺប៊ីក អ៊ិនវេសមិនហ្គ្រុប ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១)។
[6] នៅ ស៊ីវុត្ថា "កំពង់ផែទេសចរណ៍កំពតសម្រេចបាន៩០ភាគរយ" (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៩ ខែមករា ឆ្នាំ២០២២)។

អភិវឌ្ឍឆ្នេរក្នុងខេត្តកែប[7] ឬការសាងសង់កំពង់ផែសមុទ្រ និងទីក្រុងរណប ឬកោះសិប្បនិម្មិតដោយការបង្កើតទីលានវាយកូនហ្គោលហើយក៏មានតំបន់រមណីយដ្ឋានផងដែរ[8]ដូចបានរាយឈ្មោះមួយចំនួនខាងលើ។ ក្នុងខណៈដែលគម្រោងទាំងនោះពិតជាផ្តល់អត្ថប្រយោជន៍ខាងសេដ្ឋកិច្ច តែគម្រោងអភិវឌ្ឍន៍មួយចំនួននៅតាមឆ្នេរសមុទ្រខេត្តកំពត និងកែប គឺត្រួតស៊ីគ្នាទៅលើដីសហគមន៍នេសាទនៅតំបន់ឆ្នេរ។ នេះរាប់បញ្ចូលទាំងសហគមន៍នេសាទផ្សេងៗ ដែលដែននេសាទ និងសិទ្ធិ និងធនធានធម្មជាតិ និងជីវចម្រុះដែលពួកគេពឹងផ្អែកលើសម្រាប់ការរស់រានមានជីវិត និងជាការការពារពីគ្រោះធម្មជាតិ ត្រូវបានគំរាមកំហែងដោយគម្រោងអភិវឌ្ឍន៍ទាំងនោះ។

ទោះបីជាក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិបានផ្តល់នូវការការពារចំពោះដីសហគមន៍នេសាទ និងសិទ្ធិមូលដ្ឋានទាំងឡាយយ៉ាងណាក្តី[9] ក៏នៅមិនទាន់គ្រប់គ្រាន់នោះទេ ហើយ/ឬថាមិនទាន់មានការអនុវត្តឱ្យបានពេញលេញពីសំណាក់អាជ្ញាធរកម្ពុជា។[10] សិទ្ធិដែលផ្តល់នូវការធានាសុវត្ថិភាពដល់សហគមន៍នេសាទគឺតាមរយៈការចុះបញ្ជីជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ។ ទោះដូច្នេះក្តី ការចុះបញ្ជីមិនបានផ្តល់អំណាចគ្រប់គ្រាន់ឱ្យក្លាយជាម្ចាស់ដីដែលពួកគេកាន់កាប់នោះឡើយ តែផ្ទុយទៅវិញគឺក្រសួងអាចដកហូតយកមកវិញពេលណាក៏បាន។ អសុវត្ថិភាពនៃការកាន់កាប់ដីធ្លីដែលសហគមន៍រស់នៅ គឺកាន់តែធ្ងន់ធ្ងរឡើងដោយក្តីបារម្ភថានឹងអាចមានការរំសាយសហគមន៍ចេញ ដោយពុំមានការជូនដំណឹងជាមុន ដោយសារតែផលប្រយោជន៍នៃគម្រោងអភិវឌ្ឍន៍ដែលអាចផ្តល់កម្រៃនៅក្នុងការខិតខំរបស់រដ្ឋាភិបាលក្នុងការជំរុញទេសចរណ៍នៅតំបន់ឆ្នេរ។ លើសពីនេះ រដ្ឋាភិបាលបានបន្តប្រើប្រាស់ច្បាប់ជាតិដែលមានលក្ខណៈគាបសង្កត់ និងដាក់គោលដៅទៅលើសកម្មជនដីធ្លី និងប្រជាពលរដ្ឋដែលមានជម្លោះដីធ្លីជាមួយអាជ្ញាធរ ឬក្រុមហ៊ុនឯកជនដែលកំពុងប្រើប្រាស់សេរីភាពមូលដ្ឋានក្នុងការការពារដីធ្លី។[11]

ហេតុដូច្នេះហើយ សហគមន៍នេសាទនៅតែមិនទាន់ទទួលបានការការពារពេញលេញ ហើយអត្ថិភាពរបស់ពួកគេកាន់តែរងគ្រោះថ្នាក់ដោយសារតែគម្រោងអភិវឌ្ឍន៍ទាំងនេះ។ គួរកត់សម្គាល់ថា ករណីសហគមន៍នេសាទចំនួនប្រាំបី គឺសហគមន៍កំពង់សាមគ្គី ត្រពាំងសង្កែ ត្រពាំងរពៅ ចង្ហោន ព្រែកត្នោត នៅខេត្តកំពត និងសហគមន៍ភូមិថ្មី កំពង់ត្រឡាច និងអូរក្រសារ នៅខេត្តកែប ដែលរងការគំរាមកំហែងពីផែនការអភិវឌ្ឍន៍របស់

---

[7] ប៊ុត រស្មីគង្គារ "ទីក្រុងកែបទទួលបានការកែប្រែមុខមាត់ថ្មី" (ខ្មែរថាមស៍ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១)។

[8] អាក់សិនអេតកម្ពុជា ម.ស.ម.ក និង មអកសក "របាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម៖ ផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍ទៅលើធនធានបរិស្ថានសមុទ្រនៅខេត្តកំពតនិងកែប" (អាក់សិនអេតកម្ពុជា ខែតុលា ឆ្នាំ២០២១), ទំព័រទី៣ ("របាយការណ៍រួមគ្នា ចេញផ្សាយដោយ អាក់សិនអេតកម្ពុជា ម.ស.ម.ក និង ម.អ.ក.ស.ក។")។

[9] សម្រាប់ព័ត៌មានបន្ថែមអំពីក្របខណ្ឌច្បាប់ស្តីពីសហគមន៍នេសាទ សិទ្ធិដីធ្លី និងបរិស្ថាន សូមចូលទៅអាន សលាកប័ត្រព័ត៌មាន៖ សហគមន៍នេសាទនិងគម្រោងអភិវឌ្ឍន៍នៅតំបន់ឆ្នេរ របស់ ម.ស.ម.ក," (ម.ស.ម.ក ខែកុម្ភៈ ឆ្នាំ២០២១) ("ម.ស.ម.ក សលាកប័ត្រព័ត៌មានលេខ១") និង ម.ស.ម.ក "សលាកប័ត្រព័ត៌មាន៖ សហគមន៍នេសាទនិងគម្រោងអភិវឌ្ឍន៍នៅតំបន់ឆ្នេរ," (ម.ស.ម.ក ខែមេសា ឆ្នាំ២០២២) ("ម.ស.ម.ក សលាកប័ត្រព័ត៌មានលេខ២")។

[10] ក្រសួងបរិស្ថាន, ជីអ៊ីអេហ្វ, យូអិនឌីភី & ប៉េមសៀ "រដ្ឋនៃមហាសមុទ្រនិងតំបន់ឆ្នេរ ឆ្នាំ២០១៨៖ កំណើនសេដ្ឋកិច្ចព័ណ៌ខៀវប្រទេសកម្ពុជា" (ក្រសួងបរិស្ថាន ខែធ្នូ ឆ្នាំ២០១៩), §៤.១០, ទំព័រ៤៦។

[11] ម.ស.ម.ក "សលាកប័ត្រព័ត៌មាន៖ ការបណ្តេញចេញដោយបង្ខំនៅកម្ពុជាអំឡុងពេលកូវីដ១៩"(ម.ស.ម.ក ខែតុលា ឆ្នាំ២០២១); សូមអានព័ត៌មានវិទ្យុអាស៊ីសេរី "អ្នកភូមិធ្វើការតវ៉ាករណីជម្លោះដីធ្លីរ៉ាំរ៉ៃទៅសាលាក្រុង" (អាស៊ីសេរី ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២២); ឃួន ណារីម "ក្រុមហ៊ុនឈូសឆាយដីអ្នកភូមិសម្រាប់គម្រោងព្រលានយន្តហោះទោះបីជម្លោះនៅមិនទាន់បញ្ចប់" (ព័ត៌មានខេមបូចា ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២)។

ក្រុមហ៊ុនអុមនី និង ជីងគ័រ និងក្រុមហ៊ុនដទៃទៀតនៅក្នុងតំបន់ដូចមានបង្ហាញលម្អិតនៅក្នុងករណីសិក្សា[12] ខាងក្រោម។

## ៤. ករណីសិក្សាៈ សហគមន៍នេសាទក្នុងខេត្តកំពត និងកែប ប្រឈមនឹងភាពមិនច្បាស់លាស់នៃគម្រោងអភិវឌ្ឍន៍អុមនី ជីងគ័រ និងគម្រោងអភិវឌ្ឍន៍មួយចំនួនទៀត

តំបន់ឆ្នេរខេត្តកែប និងកំពត ជាភូមិឋានរស់នៅរបស់សហគមន៍នេសាទជាច្រើន។ សហគមន៍កំពង់សាមគ្គីស្ថិតនៅក្នុងឃុំកូនសត្វ ត្រពាំងសង្កែស្ថិតនៅក្នុងឃុំត្រពាំងសង្កែ ស្រុកទឹកឈូ សហគមន៍ព្រែកត្នោត ត្រពាំងរពៅ និងចង្ហោន ស្ថិតនៅក្នុងសង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត។ នៅខេត្តកែប មានសហគមន៍ភូមិថ្មី អូរក្រេសារ និងកំពង់ត្រឡាចមានទីតាំងស្ថិតនៅក្នុងក្រុងកែប។ សហគមន៍ទាំងអស់ត្រូវបានបង្កើតឡើងនៅដើមឆ្នាំ២០០០ ហើយទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា។[13]

ការនេសាទគឺជាមុខរបរចិញ្ចឹមជីវិតដ៏សំខាន់សម្រាប់សហគមន៍ទាំងនោះ មានន័យថាសមាជិកសហគមន៍ភាគច្រើនពឹងអាស្រ័យការនេសាទដើម្បីចិញ្ចឹមជីវិត និងជានាសុវត្ថិភាពស្បៀងអាហារប្រចាំគ្រួសារ និងសហគមន៍ រួមទាំងសហគមន៍ភូមិផងរបងជាមួយគ្នាផងដែរ ស្របទៅតាមការលើកឡើងរបស់សហគមន៍នេសាទដែលបានផ្តល់បទសម្ភាសន៍ដល់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។[14]ជាងនេះទៅទៀត សមាជិកសហគមន៍ដែលបានផ្តល់បទសម្ភាសន៍បានលើកឡើងថា ក្រៅតែពីប្រភពប្រាក់ចំណូលដ៏ទៀងទាត់នោះ ការនេសាទគឺជាមុខរបរប្រពៃណីតជំនាន់របស់សមាជិកសហគមន៍ ដែលភាគច្រើនបានរៀនសូត្រការធ្វើនេសាទនេះតាំងពីធំដឹងក្តីមកម្លេះ។ ដូចនេះហើយ ការបាត់បង់សហគមន៍នេសាទមិនត្រឹមតែបណ្តាលឱ្យបាត់បង់មុខរបរប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការគំរាមកំហែងដល់អនាគតកូនៗពួកគេផងដែរ។

[12] ព័ត៌មានផ្តល់ជូននៅផ្នែកទី៤បានមកពីកិច្ចសម្ភាសរបស់ ម.ស.ម.ក វៀរលែងមានសេចក្តីយោងដទៃទៀត។ ម.ស.ម.ក បានធ្វើការស្រាវជ្រាវនៅខេត្តកំពតនិងកែប នៅខែសីហា ឆ្នាំ២០២២ និងសម្ភាសជាមួយសហគមន៍នេសាទទាំងប្រាំពីរដែលប៉ះពាល់ដោយគម្រោងរបស់ក្រុមហ៊ុនអុមនី និងជីងគ័រ គឺមានសហគមន៍កំពង់សាមគ្គី ត្រពាំងសង្កែ ព្រែកត្នោត ត្រពាំងរពៅ ចង្ហោន អូរក្រេសារ និងភូមិថ្មី អាជ្ញាធរថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋាន (អង្គការមិនមែនរដ្ឋាភិបាល)។ ដើម្បីរាយការណ៍ពីករណីសិក្សានេះ ម.ស.ម.ក បានធ្វើការសម្ភាសសមាជិកមួយចំនួននៃសហគមន៍គោលដៅទាំងប្រាំពីរ និងអាជ្ញាធរភូមិ ឃុំ និងខេត្តចំនួនប្រាំនៅខេត្តកំពត និងអាជ្ញាធរឃុំ និងថ្នាក់ខេត្តចំនួនពីរនៅខេត្តកែប រួមទាំងអង្គការមិនមែនរដ្ឋាភិបាលចំនួនបួន។ លើសពីនេះ ម.ស.ម.ក បានដាក់លិខិតស្នើសុំសម្ភាសន៍ទៅអាជ្ញាធរមូលដ្ឋាននិងអាជ្ញាធរខេត្តមួយចំនួនទៀត តែត្រូវបានបដិសេធផ្តល់បទសម្ភាសន៍។

[13] របាយការណ៍រួមគ្នា ចេញផ្សាយដោយអង្គការ អាក់សិនអេតកម្ពុជា មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា នៅខែតុលា ឆ្នាំ២០២១, ទំព័រទី៣។

[14] ប្រភពដូចខាងលើ, ទំព័រ ១៥-១៦, បញ្ជាក់ដោយកិច្ចសម្ភាសរបស់ ម.ស.ម.ក ធ្វើនៅឆ្នាំ២០២១ (សូមអានសលាកប័ត្រព័ត៌មានលេខ២)។



ប្រភព: អង្គការអាក់សិនអេតកម្ពុជា

ចាប់តាំងពីខែកញ្ញា ឆ្នាំ២០១២ ដីដែលសហគមន៍ព្រែកត្នោត ត្រពាំងរពៅ និងចង្ហោនពឹងអាស្រ័យសម្រាប់ការរស់រាន ត្រូវបានគេដាក់បញ្ចូលលាយឡំគ្នានៅក្នុងគម្រោងរបស់ក្រុមហ៊ុនជីងគ័រ ប៉ាប៉ា កេត្រូលៀម រួមទាំងក្រុមហ៊ុនកំពង់ផែកំពតឡូជីសស្ទីក ខូអិលធីឌី នាពេលថ្មីៗនេះដែលចាក់ដីទៅក្នុងសមុទ្រ និងអភិវឌ្ឍឆ្នេរសមុទ្រដ៏ធំទូលាយដើម្បីធ្វើជាកំពង់ផែ មជ្ឈមណ្ឌលរីសត និងតំបន់សេដ្ឋកិច្ចពិសេស (“គម្រោងជីងគ័រ”) លើដីទំហំជាង៦០០ហិកតា និងក្រុមហ៊ុនប៉ាប៉ា កេត្រូលៀម រួមជាមួយក្រុមហ៊ុនកំពង់ផែកំពតឡូជីសស្ទីក ខូអិលធីឌីនៅលើផ្ទៃដីទំហំប្រមាណ ១.០០០ ហិកតា នៅសង្កាត់ព្រែកត្នោត ក្រុងបូគគោ ខេត្តកំពត។ នៅឆ្នាំ២០១៨ គម្រោងដ៏ធំនៃក្រុមហ៊ុនអុមនីមានគម្រោងសាងសង់កោះសិប្បនិម្មិតក្នុងគោលបំណងអភិវឌ្ឍវិស័យទេសចរណ៍(“គម្រោងអុមនី”) លើផ្ទៃដីទំហំជិត ៤.០០០ ហិកតានៅក្នុងស្រុកទឹកឈូ ខេត្តកំពត និងក្រុងកែប ខេត្តកែប បានបង្កការគំរាមកំហែងដល់សហគមន៍នេសាទក្នុងតំបន់ រួមមានសហគមន៍កំពង់សាមគ្គី ត្រពាំងសង្កែ ក្នុងខេត្តកំពត និងសហគមន៍ភូមិថ្មី កំពង់ត្រឡាច និងអូរក្រសារ។

នៅឆ្នាំ២០១៨ គម្រោងដ៏ធំនៃក្រុមហ៊ុនអុមនីចាប់ផ្តើមសាងសង់កោះសិប្បនិម្មិតបម្រើវិស័យទេសចរណ៍(“គម្រោងអុមនី”) លើដីជាង ៤.០០០ ហិកតានៅក្នុងស្រុកទឹកឈូ ខេត្តកំពត ដែលបានបង្កការគំរាមកំហែងដល់សហគមន៍នេសាទក្នុងតំបន់ រួមមានសហគមន៍កំពង់សាមគ្គី ត្រពាំងសង្កែ ភូមិថ្មី និងអូរក្រសារ ក្នុងខេត្តកែប។[15]

តាមរយៈព័ត៌មានដែល ម.ស.ម.ក ប្រមូលបាននៅក្នុងកិច្ចសម្ភាសដែលបានធ្វើនៅក្នុងឆ្នាំ២០២០ និង ២០២១ ក្រុមហ៊ុន ជីងគ័រ មិនទាន់បានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម (“ការវាយតម្លៃ”) ដែលតម្រូវដោយច្បាប់នៅឡើយទេ[16] ខណៈដែលក្រុមហ៊ុនអុមនី បានប្រគល់ភារកិច្ចក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដល់ក្រុមហ៊ុនផ្តល់ប្រឹក្សា គ្រីអេទីវ ហ្គ្រីន ឌីសាញ ខូអិលធីឌី។[17] នៅពេលនោះ ម.ស.ម.ក មិនអាចស្នើសុំព័ត៌មានវាយតម្លៃពេញលេញ ឬលម្អិតអំពីលទ្ធផលនៃការរកឃើញហេតុប៉ះពាល់បរិស្ថាននិងសង្គមនោះបានទេ។ មិនមានសហគមន៍ ឬអាជ្ញាធរថ្នាក់ក្រោមជាតិណាមួយដែលយើងបានសម្ភាសកាលពីឆ្នាំ២០២២ មានព័ត៌មានបច្ចុប្បន្នភាពស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃក្រុមហ៊ុនទាំងពីរនេះ ក៏ដូចជា

[15] នៅក្នុងផែនទីនេះមានដាក់បង្ហាញតែសហគមន៍ដែលរងផលប៉ះពាល់ដោយសារគម្រោងក្រុមហ៊ុនជីងគ័រ និងអុមនី ប៉ុណ្ណោះ ដោយមិនទាន់ធ្វើបច្ចុប្បន្នភាពដាក់បញ្ចូលសហគមន៍ដែលរងផលប៉ះពាល់ដោយសារក្រុមហ៊ុនប៉ាប៉ា កេត្រូលៀម និងកំពង់ផែកំពតឡូជីសស្ទីក ខូអិលធីឌី ឡើយ។

[16] សូមអានសលាកប័ត្រព័ត៌មានលេខ១ របស់ ម.ស.ម.ក។

[17] សូមអានសលាកប័ត្រព័ត៌មានលេខ១ និងលេខ២ របស់ ម.ស.ម.ក។

ក្រុមហ៊ុន ប៉ាប៉ា កេត្រូលៀម និងក្រុមហ៊ុនកំពង់ផែកំពតឡូជីសស្ទីក ខូអិលធីឌីផងដែរ ហើយរបាយការណ៍ទាំងនោះនៅតែមិនទាន់អាចស្វែងរកបាននៅឡើយទេ។ អង្គការមូលដ្ឋានមួយដែលបានផ្តល់បទសម្ភាសន៍បានរាយការណ៍ថា ធ្លាប់បានជួបនិងជជែកជាមួយតំណាងមកពីក្រសួងបរិស្ថាន នៅសិក្ខាសាលាមួយកាលពីខែសីហា ឆ្នាំ ២០២២ បានបញ្ជាក់ថាក្រសួងបរិស្ថានបានស្នើសុំទៅក្រុមហ៊ុនអុមនីដើម្បីពិនិត្យមើលរបាយការណ៍វាយតម្លៃរបស់ខ្លួនឡើងវិញដូចបានរាយការណ៍នៅក្នុងសលាកប័ត្រព័ត៌មុន។[18] អ្នកផ្តល់បទសម្ភាសន៍ថែមទាំងបានផ្តល់ព័ត៌មានថា ធ្លាប់បានជួបតំណាងអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលបាននិយាយជាមួយមន្ត្រីម្នាក់នៃនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម របស់ក្រសួងបរិស្ថានដែលបាននិយាយថាបានស្នើឱ្យក្រុមហ៊ុនទាំងពីរគឺអុមនី និងជីងគ័រ ពិនិត្យរបាយការណ៍វាយតម្លៃរបស់ពួកគេឡើងវិញផងដែរ។ ម.ស.ម.ក ក៏មិនអាចសុំការបញ្ជាក់បន្ថែមនូវព័ត៌មានទាំងនេះពីអាជ្ញាធរពាក់ព័ន្ធបានទេ។ ស្រដៀងគ្នានេះដែរចាប់តាំងពីការធ្វើសម្ភាសន៍កន្លងមក គឺមិនទាន់បានទទួលព័ត៌មានថាមានការប្រជុំ ឬការពិគ្រោះយោបល់រវាងក្រុមហ៊ុនទាំងពីរជាមួយសហគមន៍ជាថ្មីទៀតទេ។ មិនមានអ្នកផ្តល់បទសម្ភាសន៍ណាម្នាក់មានបច្ចុប្បន្នភាពព័ត៌មានអំពីការវិវត្តនៃគម្រោងក្រុមហ៊ុនអុមនី និងជីងគ័រនេះឡើយ ក្នុងខណៈដែលសហគមន៍មួយចំនួនដែលផ្តល់បទសម្ភាសន៍បានត្អូញត្អែរថាក្រុមហ៊ុនប៉ាប៉ា កេត្រូលៀម និងក្រុមហ៊ុនកំពង់ផែកំពតឡូជីសស្ទីក ខូអិលធីឌី បានចាក់ដីទៅក្នុងសមុទ្របណ្តាលឱ្យការនេសាទរបស់ពួកគេជួបការលំបាក ដោយសារតែទីតាំងនេសាទរួមតូចទៅៗ ពីមួយថ្ងៃទៅមួយថ្ងៃ និងបណ្តាលឱ្យមានភក់ជាច្រើនហៀរហូរចូលមកក្នុងព្រែក ដែលជាផ្លូវសម្រាប់ពួកគាត់អូសទូកយកចេញទៅទីនេសាទក្នុងសមុទ្រ និងអ្វីដែលសហគមន៍នេសាទកាន់តែព្រួយបារម្ភទៅទៀតនោះគឺថា អាជ្ញាធរមូលដ្ឋានដែលចូលរួមប្រជុំមួយកាលពីខែកក្កដា ឆ្នាំ២០២២ បាននិយាយថា ទីតាំងរបស់សហគមន៍ចង្ហោនត្រូវបានអនុញ្ញាតរួចហើយឱ្យរំកិលទៅតាំងមួយផ្សេងទៀត ហើយទីតាំងរបស់សហគមន៍ព្រែកត្នោត និងត្រពាំងរពៅក៏នឹងត្រូវរំកិលទៅទីតាំងថ្មីដូចគ្នាដែរ នេះបើយោងតាមផែនទីមួយដែល ម.ស.ម.ក បានទទួលពីអាជ្ញាធរកាលពីខែសីហា ឆ្នាំ២០២២។

ក្រុមហ៊ុនជីងគ័រមានរោងម៉ាស៊ីនកិនស្រូវចំនួនពីរនៅលើផ្ទៃដីប្រហែល៣០ហិកតា ជាដីឯកជននៅក្នុងសង្កាត់ព្រែកត្នោត។ នៅពេលសាកសួរថាតើរោងម៉ាស៊ីនកិនស្រូវទាំងពីរនៅតែបង្កផលលំបាកដល់អ្នកភូមិឬទេ? (ឧទាហរណ៍ ក្លិនអាក្រក់ កាកសំណល់បង្ហូរចូលក្នុងទឹកសមុទ្រ) ដូចព័ត៌មានដែលទទួលបានពេលធ្វើការស្រាវជ្រាវកន្លងទៅ សហគមន៍ដែលពាក់ព័ន្ធបានឆ្លើយថា រោងម៉ាស៊ីនមួយក្នុងចំណោមរោងម៉ាស៊ីនទាំងពីរបានផ្អាកដំណើរការមួយរយៈមកហើយ។ ពួកគាត់ថែមទាំងបានរៀបរាប់ពីក្រុមហ៊ុនថៃមួយបានជួលដីពីក្រុមហ៊ុនជីងគ័រទៀតផង។ សហគមន៍ព្រែកត្នោតបានបន្ថែមថា ប្រតិបត្តិការរបស់ក្រុមហ៊ុនថៃនោះនៅតែបង្កឱ្យមានក្លិនអាក្រក់និងកាកសំណល់ហូរចូលទៅក្នុងសមុទ្រ បណ្តាលឱ្យផលប៉ះពាល់ដល់បរិស្ថាន ជីវៈចម្រុះ និងប៉ះពាល់

[18] សូមអានសលាកប័ត្រព័ត៌មានលេខ២ របស់ ម.ស.ម.ក។

ដល់ប្រាក់ចំណូលរបស់អ្នកប្រកបរបរនេសាទ។ ចំពោះសហគមន៍ត្រពាំងរពៅបានរាយការណ៍ថា ពេលនេះផលប៉ះពាល់ទាំងនោះមានភាពប្រសើរជាងមុន។

កង្វះព័ត៌មានអំពីគម្រោងអភិវឌ្ឍន៍បន្តក្លាយជាក្តីកង្វល់យ៉ាងខ្លាំង។ ព័ត៌មានអំពីគម្រោងអភិវឌ្ឍន៍ក្នុងតំបន់ទាំងនោះនៅតែបង្កភាពភ័យខ្លាយសម្រាប់សហគមន៍ រួមទាំងកង្វះការយល់ដឹងអំពីគម្រោងទាំងអស់របស់សហគមន៍រងគ្រោះទៅលើព័ត៌មានអំពីគម្រោងអភិវឌ្ឍន៍ ដែលព័ត៌មានទាំងនោះ សហគមន៍បានដឹងឮភាគច្រើនមកពីអង្គការមូលដ្ឋាន ឬក្រុមហ៊ុនផ្ទាល់នៅពេលពួកគេបានមកជួបសហគមន៍ដើម្បីស្នើសុំការយល់ព្រមគាំទ្រគម្រោងអភិវឌ្ឍន៍។ សហគមន៍បាននិយាយថា ខ្លួនកម្របានទទួលព័ត៌មានពីអាជ្ញាធរមូលដ្ឋាន ឬអាជ្ញាធរថ្នាក់ខេត្តណាស់ ដែលទំនងជាពួកគាត់ផ្ទាល់ក៏ពុំមានព័ត៌មានគ្រប់គ្រាន់ ឬស្ទាក់ស្ទើរក្នុងការបញ្ចេញព័ត៌មានទាំងប៉ុន្មានដែលពួកគាត់បានដឹង។ ក្រុមហ៊ុនអុមនី និងជីងគ័រ មិនមានសកម្មភាពអ្វីទេគិតចាប់តាំងពីឆ្នាំ២០១៩ និង២០២០មក។ ពុំមានអ្នកផ្តល់បទសម្ភាសន៍ណាម្នាក់ រួមទាំងអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរថ្នាក់ខេត្តផងដែរដឹងច្បាស់ថាតើក្រុមហ៊ុននៅតែបន្តប្រតិបត្តិការ និងអំពីស្ថានភាពបច្ចុប្បន្ននៃគម្រោងអភិវឌ្ឍន៍ទាំងនោះឡើយ។ ទោះជាយ៉ាងណា នៅក្នុងខែសីហា ឆ្នាំ២០២២ ម.ស.ម.ក បានព្យាយាមទាក់ទងតាមទូរស័ព្ទទៅបុគ្គលិករបស់ក្រុមហ៊ុនជីងគ័រម្នាក់ ដែលបាននិយាយយ៉ាងខ្លីថា ក្រុមហ៊ុនកំពុងតែដំណើរការជារៀងរាល់ថ្ងៃ ហើយព័ត៌មានស្រដៀងគ្នានេះដែរដែល ម.ស.ម.ក បានទទួលពីមន្ត្រីម្នាក់នៅពេលកំពុងសម្ភាសនោះបាននិយាយថា ក្រុមហ៊ុនជីងគ័រ កំពុងដំណើរការរត់ឯកសារយ៉ាងសកម្មដើម្បីក្រុមហ៊ុនអាចប្រតិបត្តការបន្តទៀត ខណៈដែលតំណាងម្នាក់របស់ក្រុមហ៊ុននេះដែលបានចូលរួមសិក្ខាសាលាមួយកាលពី ខែមិថុនា ឆ្នាំ២០២២ បាននិយាយប្រាប់យ៉ាងសង្ខេបទៅអ្នកចូលរួមថា ជាជំហររបស់ក្រុមហ៊ុនគឺអាស្រ័យទៅលើយោបល់សហគមន៍មូលដ្ឋាន។ ប្រសិនបើមានការគាំទ្រពីសហគមន៍មូលដ្ឋានលើសពី ៦០ ភាគរយ នោះក្រុមហ៊ុននឹងបន្តគម្រោងរបស់ខ្លួន ប៉ុន្តែបើការគាំទ្រពីសហគមន៍មូលដ្ឋានតិចជាងនេះ ក្រុមហ៊ុន នឹងមិនបន្តគម្រោងនោះទៀតទេ។

អ្នកផ្តល់បទសម្ភាសន៍ខ្លះបានផ្តល់ព័ត៌មានអំពីការទន្ទ្រានយកដីសហគមន៍ ដោយបុគ្គលមានអំណាចមួយចំនួន ដូចជាផ្នែកមួយនៃដីដែលសហគមន៍នេសាទត្រពាំងសង្កែបានដាំដើមកោងកាង ត្រូវបានកាន់កាប់ដោយមន្ត្រីម្នាក់ ហើយផ្ទៃដីប្រមាណជា ១២ហិកតា របស់សហគមន៍កំពង់សាមគ្គីត្រូវបានបុគ្គលមានឥទ្ធិពលចំនួន៥នាក់ប៉ុនប៉ងទន្ទ្រានយក និងផ្ទៃដីទំហំប្រមាណ ២.០០០ ម៉ែត្រការ៉េរបស់សហគមន៍ព្រែកត្នោតត្រូវបានបុគ្គលមិនស្គាល់អត្តសញ្ញាណម្នាក់ទន្ទ្រានយកផងដែរ ដោយពុំមានការចាត់វិធានការច្បាប់ណាមួយមានប្រសិទ្ធភាពទៅលើករណីរំលោភបំពានយកដីសហគមន៍ទាំងនោះឡើយ។

ពេលសម្ភាសថាតើពួកគេបានធ្វើអ្វីដើម្បីឃ្លាំមើល និងទប់ស្កាត់ផលប៉ះពាល់សិទ្ធិមនុស្សនិងបរិស្ថានដែលបង្កដោយក្រុមហ៊ុនក្នុងតំបន់រួមមានតំបន់ឆ្នេរ អាជ្ញាធរថ្នាក់ក្រោមជាតិបានគូសបញ្ជាក់តាមរយៈការផ្តល់បទសម្ភាសន៍ថាពួកគេបានជួយសហគមន៍នេសាទក្នុងការឃ្លាំមើលសកម្មភាពល្មើសច្បាប់នានា និងចាត់វិធានការភ្លាមៗដើម្បីបញ្ឈប់សកម្មភាពទាំងអស់នោះ។ ចំណែកឯអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានផ្តល់បទសម្ភាសន៍បានលើកឡើងថាយោងតាមការសង្កេតតាមដានកន្លងមក អាជ្ញាធរមិនមានយន្តការអ្វីជាក់លាក់

ក្នុងការតាមដានឱ្យបានត្រឹមត្រូវនិងកម្រិតផលប៉ះពាល់សិទ្ធិមនុស្ស និងបរិស្ថាននៃក្រុមហ៊ុននៅក្នុងខេត្តទាំងពីរនេះទេ។ មានអង្គការមិនមែនរដ្ឋាភិបាលមួយបានបន្ថែមថា អាជ្ញាធរមិនបានអនុវត្តច្បាប់ដែលមានឱ្យបានពេញលេញក្នុងការបង្ការផលប៉ះពាល់ទាំងនោះឡើយ។ អង្គការមួយទៀត បានលើកឡើងពីចេតនាថា ចង់ឃើញអាជ្ញាធរមានសមត្ថកិច្ចថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់ចំពោះផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍នៅក្នុងតំបន់ទាំងពីរនេះ រួមទាំងមានចាត់វិធានការតឹងរឹងបន្ថែមទៀតក្នុងការការពារសហគមន៍នេសាទពីក្រុមហ៊ុន ជាជាងស្វែងរកការសម្របសម្រួលក្រោយមានបញ្ហា និងរំកិលទីតាំងសហគមន៍ទៅកន្លែងផ្សេងទៀត ដើម្បីផ្តល់ដីពួកគេទៅឱ្យក្រុមហ៊ុន។ សហគមន៍ក៏បានយល់ស្របចំពោះការលើកឡើងនេះដែរ។ សហគមន៍នេសាទនៃខេត្តទាំងពីរបាននិយាយថា ពួកគេតែងលើកឡើងនូវបញ្ហាប្រឈមពីគម្រោងអភិវឌ្ឍន៍ជារឿយៗទៅអាជ្ញាធរពាក់ព័ន្ធ ដូចជារដ្ឋបាលជលផលខេត្ត ឬមេភូមិ និងមេឃុំ ក្រៅពីអង្គការមិនមែនរដ្ឋាភិបាល ជូនកាលរាយការណ៍ទៅសារព័ត៌មាន ប៉ុន្តែបានសង្កត់ធ្ងន់ពីតម្រូវការនិងចំណាត់ការបន្ថែមពីអាជ្ញាធរ។ សហគមន៍នេសាទបានស្នើសុំឱ្យអាជ្ញាធរជួយសហគមន៍ក្នុងការការពារដីនិងការពារសហគមន៍ពីការរំលោភយកដីធ្លី និងហាមឃាត់គម្រោងអភិវឌ្ឍន៍ពីការដាក់គម្រោងនៅលើដីសហគមន៍ដើម្បីអភិរក្សសហគមន៍និងរក្សាមុខរបរនេសាទជាប្រពៃណី។ សហគមន៍បានអំពាវនាវឱ្យអាជ្ញាធរ និងក្រុមហ៊ុនត្រូវជូនដំណឹងដល់សហគមន៍ពីគម្រោងអភិវឌ្ឍន៍នានា ដោយប្រកាន់ខ្ជាប់នូវការពិគ្រោះយោបល់ជាមួយសហគមន៍រងគ្រោះ ហើយធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមប្រកបដោយយុត្តិធម៌ និងតម្លាភាពដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានផ្សេងៗដល់ដីសហគមន៍ និងត្រួតស៊ីគ្នាលើដីសហគមន៍។

ភាពមិនច្បាស់លាស់ជាបន្តបន្ទាប់ដែលសហគមន៍ពើបប្រទះ ដោយសារតែផែនការរបស់ប្រទេសចំពោះការអភិវឌ្ឍនៅតំបន់ឆ្នេរ បានបង្កផលប៉ះពាល់ទៅដល់សុខភាពផ្លូវចិត្ត និងសុខុមាលភាពរបស់ប្រជាសហគមន៍ផងដែរ។ អ្នកផ្តល់សម្ភាសន៍បានរាយការណ៍ពីអារម្មណ៍មិនសប្បាយចិត្ត ធាប់ខឹង និងតានតឹងដោយសារគម្រោងអភិវឌ្ឍន៍ និងព្រួយបារម្ភពីការបាត់បង់មុខរបរនេសាទនិងប្រាក់ចំណូល។ សហគមន៍ខ្លះនិយាយថាពួកគេគេងមិនលក់ព្រោះត្បិតដីកំពុងត្រូវបានគេទន្ទ្រានយក។ ប្រធានសហគមន៍ម្នាក់បានប្រាប់ ម.ស.ម.ក ថាគាត់ចង់លាឈប់ពីតួនាទីជាប្រធានសហគមន៍ព្រោះតែមានភាពតានតឹង ក៏ប៉ុន្តែសមាជិករបស់គាត់បានលើកទឹកចិត្តឱ្យគាត់នៅបន្តទៀត។ អ្នកផ្តល់សម្ភាសន៍ខ្លះទៀតបានបន្ថែមថាអារម្មណ៍អវិជ្ជមានទាំងនោះជូនកាលប៉ះពាល់ដល់អារម្មណ៍ និងបង្កទៅជាការឈ្លោះប្រកែកក្នុងគ្រួសារឬជាមួយអ្នកជិតខាង ហើយអាចឈានទៅដល់ការប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារជាដើម។ លើសពីនេះទៀត ក្នុងការសម្ភាសជាមួយសហគមន៍ចំនួនពីរផ្សេងគ្នា ឥទ្ធិពលនៃគម្រោងអភិវឌ្ឍន៍បានបង្កើតឱ្យមានការមិនទុកចិត្តគ្នាក្នុងចំណោមសមាជិក ជាមួយនឹងគណៈកម្មការសហគមន៍ដោយបានលើកឡើងពីការសង្ស័យថា គណៈកម្មការសហគមន៍បានព្រមព្រៀងជាមួយនឹងក្រុមហ៊ុន ហើយត្រូវបានចោទថាបានប្រគល់ដីសហគមន៍ទៅឱ្យក្រុមហ៊ុន។ ខណៈដែលសមាជិកគណៈកម្មការសហគមន៍ដែលកំពុងបារម្ភបានច្រានចោលរាល់ការចោទប្រកាន់ និងបានអះអាងថាពួកគេក៏បារម្ភនិងខកចិត្តដូចសមាជិកសហគមន៍ដែរ ការណ៍នេះបង្កឱ្យមានភាពតានតឹងក្នុងរង្វង់សហគមន៍ផងដែរ។

សហគមន៍នេសាទស្ថិតនៅក្នុងភាពភ័យខ្លាចជាប់ជានិច្ចពីគម្រោងអភិវឌ្ឍន៍ ហើយបារម្ភថាបើក្រុមហ៊ុនចាប់ដំណើរការគម្រោង សហគមន៍នឹងបាត់បង់អ្វីគ្រប់យ៉ាងរួមមានទាំងដី ធនធានធម្មជាតិដែលពួកគេពឹងអាស្រ័យដើម្បីចិញ្ចឹមជីវិត និងការនេសាទជាប្រពៃណី ហើយនិងអនាគតកូនៗរបស់ពួកគេ។

## ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

គម្រោងអភិវឌ្ឍន៍នៅតែបង្កការគំរាមកំហែងធ្ងន់ធ្ងរដល់សហគមន៍នេសាទតំបន់ឆ្នេរក្នុងប្រទេសកម្ពុជា និងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋកម្ពុជារាប់ពាន់នាក់។ ក្នុងខណៈដែលគម្រោងអភិវឌ្ឍន៍អាចផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចជាតិ ក៏សំខាន់ណាស់ដែរ ដែលប្រយោជន៍សហគមន៍នេសាទគួរត្រូវបានពិចារណាយ៉ាងត្រឹមត្រូវ និងត្រូវបានរាយការណ៍ពេញលេញ និងចូលរួមពិគ្រោះយោបល់នៅពេលគម្រោងអភិវឌ្ឍន៍ត្រូវបានពិចារណាធ្វើនៅតំបន់ឆ្នេរដើម្បីធានាថាកំណើនសេដ្ឋកិច្ចមិនកើតចេញពីការរំលោភបំពានសិទ្ធិមនុស្ស។ ដូចនេះ ម.ស.ម.ក សូមរំលឹកឡើងវិញនូវអនុសាសន៍ដែលធ្លាប់បានផ្តល់ជូនកន្លងមកទៅរាជរដ្ឋាភិបាលកម្ពុជា និងធុរកិច្ច ដែលកំពុងប្រតិបត្តិការអាជីវកម្មនៅក្នុងប្រទេសកម្ពុជាដូចតទៅៈ

### អនុសាសន៍ចំពោះរាជរដ្ឋាភិបាលកម្ពុជា

១. ពង្រឹងការអនុវត្តតាម **ក្របខណ្ឌច្បាប់ឱ្យបានត្រឹមត្រូវ** អនុលោមទៅតាមច្បាប់ជាតិ រួមមាន ច្បាប់ស្តីពីជលផល ស្របតាមគោលការណ៍ការអនុវត្តដោយប្រសើរដែលមានចែងនៅក្នុងគោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពី អភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការគ្រប់គ្រងដី ជលផល និងព្រៃឈើ ក្នុងបរិបទសុវត្ថិភាពចំណីអាហារជាតិ និងគោលការណ៍ស្ម័គ្រចិត្តសម្រាប់ធានានិរន្តរភាពជលផលខ្នាតតូចក្នុងបរិបទសុវត្ថិភាពចំណីអាហារ និងការលុបបំបាត់ភាពក្រីក្រ។ នេះក៏គួររួមបញ្ចូលនូវដំណើរការដោយប្រក្រតីដើម្បីទទួលស្គាល់ ការពារ និងសម្របសម្រួលសិទ្ធិស្របច្បាប់នៃសហគមន៍នេសាទចំពោះដែននេសាទ និងដីនៅជុំវិញនោះ។

២. ចាត់វិធានការ **ពង្រឹងសមត្ថភាពអាជ្ញាធរមូលដ្ឋាន និងតួអង្គសំខាន់ៗ** ឱ្យយល់ដឹងពី **សិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់របស់សហគមន៍នេសាទ** រួមមានគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍ សម្រាប់អាជ្ញាធរមូលដ្ឋានដើម្បី**ពង្រឹងសមត្ថភាពអាជ្ញាធរមូលដ្ឋាន និងតួអង្គសំខាន់ៗដទៃទៀត**ឱ្យយល់ពី**សិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់របស់សហគមន៍នេសាទ** រួមមានគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍសម្រាប់អាជ្ញាធរមូលដ្ឋានបញ្ជាក់ឬចេញប័ណ្ណកម្មសិទ្ធិឱ្យសហគមន៍។

៣. **ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះការរំលោភបំពានសិទ្ធិមនុស្សទាំងអស់** និងធានាថាដំណោះស្រាយបានឆ្លើយតបនឹងតម្រូវការដែលមានប្រសិទ្ធភាពនៃគោលការណ៍លេខ៣១[19] នៃគោលការណ៍ណែនាំ។

៤. ត្រូវធានាថាការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍រងគ្រោះត្រូវបានធ្វើមុនពេលចុះហត្ថលេខាអនុញ្ញាតឱ្យដំណើរការគម្រោងអភិវឌ្ឍន៍ហើយថាសហគមន៍ត្រូវទទួលបានព័ត៌មាន និងមានការព្រមព្រៀងជាមុនៗពេលប្រគល់សិទ្ធិឱ្យវិនិយោគ ឬឯកជននូវដែននេសាទ។

៥. ស្នើឱ្យមាន**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមច្បាស់លាស់មុនពេលអនុញ្ញាតឱ្យធ្វើការអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធ ឬតំបន់សេដ្ឋកិច្ចពិសេស** ហើយត្រូវធានាថា សហគមន៍រងគ្រោះនិងសាធារណជនទទួលបានរបាយការណ៍ទាំងនោះទាន់ពេលវេលា និងអនុវត្តយន្តការស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រាប់បញ្ចូលទាំងគោលការណ៍ណែនាំលេខ១៨។[20]

៦. អភិវឌ្ឍ និងបង្កើត **ផែនការសកម្មភាពថ្នាក់ជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស** ដោយមានការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលដើម្បីផ្សព្វផ្សាយ និងអនុវត្តតាមគោលការណ៍ណែនាំ។ និង

៧. **បញ្ឈប់ការប្រើប្រាស់ច្បាប់គាប់សង្កត់និងយាយីសកម្មជនដីធ្លី និងប្រជាពលរដ្ឋ** ដែលមានជម្លោះដីធ្លីជាមួយអាជ្ញាធរ និងក្រុមហ៊ុនចំពោះការប្រើប្រាស់សេរីភាពមូលដ្ឋានក្នុងការការពារសិទ្ធិដីធ្លី។

## អនុសាសន៍ចំពោះធុរកិច្ច

៨. **អនុវត្តគោលការណ៍ពិនិត្យដ៏ត្រឹមត្រូវ** មុនចាប់ផ្តើមរាល់ប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ដោយអនុលោមទៅតាមគោលការណ៍លេខ ១៥ ១៧ និង ១៨ នៃគោលការណ៍ណែនាំ។[21]

[19] សូមចូលទៅមើលគោលការណ៍លេខ៣១ ៖ ដើម្បីធានាដល់ប្រសិទ្ធភាពនៃយន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការទាំងរបស់រដ្ឋ និងមិនមែនរបស់រដ្ឋ យន្តការទាំងនោះគួរតែ (ក) ស្របច្បាប់ (ខ) អាចប្រើប្រាស់បាន (គ) អាចព្យាករណ៍បាន (ឃ) សមធម៌ (ង) តម្លាភាព (ច) សិទ្ធិជានិរន្ត (ឆ) ប្រភពនៃការសិក្សាជាបន្ត និង (ជ) ផ្អែកលើការចូលរួម និងការសន្ទនា។

[20] សូមចូលទៅមើលគោលការណ៍លេខ១៨ ៖ ដើម្បីវាស់វែងស្ទង់ហានិភ័យខាងសិទ្ធិមនុស្ស សហគ្រាសពាណិជ្ជកម្មគួរតែកំណត់ និងវាយតំលៃលើការប៉ះពាល់ធ្ងន់ធ្ងរជាក់ស្តែង ឬជាសក្តានុពលណាមួយលើសិទ្ធិមនុស្ស ដែលពួកគេអាចជាប់ពាក់ព័ន្ធតាមរយៈសកម្មភាពផ្ទាល់របស់ពួកគេ ឬជាលទ្ធផលនៃទំនាក់ទំនងខាងធុរកិច្ចរបស់ពួកគេ។

[21] សូមចូលទៅមើលគោលការណ៍លេខ១៥ ៖ ដើម្បីបំពេញតាមទំនួលខុសត្រូវគោរពសិទ្ធិមនុស្សរបស់ខ្លួន សហគ្រាសពាណិជ្ជកម្ម គួរតែរៀបចំបង្កើតគោលនយោបាយ និងដំណើរការប្រតិបត្តិការសមស្របទៅតាមទំហំ និងកាលៈទេសៈ។ គោលការណ៍លេខ១៧ ៖ ដើម្បីកំណត់ បង្ការ កាត់បន្ថយ និងមានគណនេយ្យភាពចំពោះរបៀប ដែលពួកគេដោះស្រាយចំពោះការប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស សហគ្រាសពាណិជ្ជកម្មទាំងអស់ គួរតែធ្វើការពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្ស។ ដំណើរការនោះគួរតែ រួមបញ្ចូលការវាយតំលៃអំពីផលប៉ះពាល់ជាក់ស្តែង និងជាសក្តានុពលលើសិទ្ធិមនុស្ស ការបូកបញ្ចូលនិងចាត់វិធានការចំពោះការរកឃើញ ការតាមដានការឆ្លើយតប និងការប្រាស្រ័យទាក់ទងលើរបៀបដោះស្រាយការប៉ះពាល់ទាំងនោះ។ គោលការណ៍លេខ១៨ ៖ ដើម្បីវាស់វែងស្ទង់ហានិភ័យខាងសិទ្ធិមនុស្ស សហគ្រាសពាណិជ្ជកម្មគួរតែកំណត់ និងវាយតំលៃលើការ ប៉ះពាល់ធ្ងន់ធ្ងរជាក់ស្តែង ឬជាសក្តានុពលណាមួយលើសិទ្ធិមនុស្ស ដែលពួកគេអាចជាប់ពាក់ព័ន្ធតាមរយៈសកម្មភាពផ្ទាល់របស់ពួកគេ ឬជាលទ្ធផលនៃទំនាក់ទំនងខាងធុរកិច្ចរបស់ពួកគេ។

៩. **ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម** ឱ្យមានការចូលរួមពីសហគមន៍ដែលរងផលប៉ះពាល់ និងសាធារណជនឱ្យបានទាន់ពេលវេលា និងដាក់ចេញនូវយន្តការត្រួតពិនិត្យការអនុវត្តដោយអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិមានដូចជាគោលការណ៍លេខ១៨[22]នៃគោលការណ៍ណែនាំ។

១០. ពិគ្រោះយោបល់ជាមួយ **សហគមន៍រងគ្រោះ អ្នកពាក់ព័ន្ធសំខាន់ៗ និងអាជ្ញាធរ** ប្រកបដោយអត្ថន័យ ទាន់ពេលវេលា និងមានតម្លាភាព យកទៅគិតគូរ និងដោះស្រាយនូវកង្វល់របស់ពួកគេ។

១១. **ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះរាល់ការរំលោភបំពានសិទ្ធិមនុស្ស** ហើយធានាថារាល់ដំណោះស្រាយឆ្លើយតបទៅនឹងតម្រូវការប្រកបដោយប្រសិទ្ធភាពនៃគោលការណ៍ណែនាំលេខ៣១[23] និង

១២. បង្កើត**យន្តការបណ្តឹងសាទុក្ខកម្រិតប្រតិបត្តិប្រកបដោយប្រសិទ្ធភាព អាចដំណើរការ និងមានតម្លាភាព** ដើម្បីឱ្យអ្នករងផលប៉ះពាល់ធ្ងន់ធ្ងរពីសកម្មភាពសាជីវកម្មស្របតាមគោលការណ៍លេខ២៩[24] នៃគោលការណ៍ណែនាំ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកលោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងធានាសុវត្ថិភាពសិទ្ធិកាន់កាប់និងគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិសម្រាប់សហគមន៍នេសាទងាយរងគ្រោះនៅតំបន់ឆ្នេរនៃប្រទេសកម្ពុជា តាមរយៈទូរស័ព្ទលេខ (+៨៥៥) ១២ ៩៤១ ២០៦ ឬអ៊ីមែល vann.sophath@cchrcambodia.org.

–ចប់–

[22] ប្រភពដូចខាងលើ នៅក្នុងលេខយោងទី២០ នៃសលាកបត្រព័ត៌មាននេះ។

[23] ប្រភពដូចខាងលើ នៅក្នុងលេខយោងទី១៩ នៃសលាកបត្រព័ត៌មាននេះ។

[24] សូមចូលទៅមើលគោលការណ៍លេខ២៩ ៖ ដើម្បីបង្កភាពងាយស្រួលសម្រាប់ការដោះស្រាយឱ្យបានឆាប់សហ័ស និងដោយផ្ទាល់ សហគ្រាសពាណិជ្ជកម្មនានាគួរតែបង្កើត ឬចូលរួមនៅក្នុងយន្តការដោះស្រាយកំរិតប្រតិបត្តិការដ៏មានប្រសិទ្ធភាព សម្រាប់បុគ្គល និងសហគមន៍នានាដែលអាចទទួលរងការប៉ះពាល់ធ្ងន់ធ្ងរ។